# សេចក្តីថ្លែងការរួមរបស់សហគមន៍
# សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី
# គំរោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម ២ កំលាំង ៤០០ មេហ្គាវ៉ាត់
# ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១

យើងខ្ញុំទាំងអស់គ្នា ជាតំណាងជនជាតិដើមភាគតិចដែលរស់នៅតាមដង ទន្លេសេសាន ទន្លេស្រែពក និង ទន្លេសេកុង ដែលមានចំនួនប្រជាជនរស់នៅសរុបចំនួនជាង ៥០០០គ្រួសារ មកពីខេត្តស្ទឹងត្រែង (ចំនួន៦ឃុំ១៨ភូមិ) និង ខេត្តរតនៈគិរី (ចំនួន ៦ស្រុក ២១ឃុំ និង ៧៤ភូមិ) ដែលមានតំណាងអ្នកភូមិចំនួន ៦៨នាក់ ស្រី២៩នាក់ ដែលកន្លងមកធ្លាប់បានរងទុក្ខវេទនា ទទួលរងផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដោយសារការសង់ទំនប់វារីអគ្គិសនីយ៉ាលី ក្នុងប្រទេសវៀតណាម ។ ដោយសារតែគំរោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២នេះនឹងសាងសង់នៅលើតួទន្លេ សេសាន ខេត្តស្ទឹងត្រែង ដែលមានកំលាំង ៤០០មេហ្គាវ៉ាត់ នឹងត្រូវចាប់ផ្តើមនាពេលឆាប់ៗខាងមុខនេះ ទើបថ្ងៃនេះ យើងខ្ញុំទាំងអស់គ្នាបានមកជួបជុំគ្នាជាថ្មីម្តងទៀតដើម្បីសំដែងនូវក្តីកង្វល់ និងសំណូមពរយ៉ាងទទូចដល់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រុមហ៊ុន សូមយកក្តីកង្វល់ និងសំណូមពរដែលទាក់ទងទៅនឹងផែនការសង់ទំនប់វារីអគ្គិសនី សេសានក្រោម២ ទៅពិចារណាឡើងវិញ ដូចតទៅ:

*១. ពិនិត្យឡើងវិញពីពីគុណភាពនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមរបស់គំរោងទំនប់សេសានក្រោម២ ដែលមិនទាន់អាចទទួលយកបានសំរាប់សហគមន៍ទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលនៅឡើយទេ ជាមួយនឹងការផ្តល់សំណងអោយបានសមស្រប ដូចជា :*

- ពិនិត្យឡើងវិញនូវវិធានការកាត់បន្ថយហេតុប៉ះពាល់នានានៅក្នុង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ក្រុមហ៊ុនមិនទាន់ធ្វើការសិក្សាចំពោះសហគមន៍ដែលរងផលប៉ះពាល់ដោយប្រយោលនៅផ្នែកខាងលើ និងខាងក្រោមនៃទំនប់ ( ទន្លេសេសាន និងទន្លេស្រែពក ) បន្ថែមទាំងផ្តល់សំណងសមស្រប
- ប្រសិនបើទំនប់សេសានក្រោម២ត្រូវបានសាងសង់ពិតមែននោះសហគមន៍នឹងប្រឈមនូវបញ្ហាដូចជា :
    - ✓ ការធ្វើដំណើរផ្លូវទឹកត្រូវរាំងស្ទះ និងបាត់បង់
    - ✓ បាត់បង់ការរកប្រាក់ចំណូលពីធនធានត្រី និងទន្លេ
    - ✓ ទឹកជំនន់កើនឡើង
    - ✓ បាត់បង់ទ្រព្យសម្បត្តិសហគមន៍

- ✓ បាត់បង់ជីវៈចំរុះក្នុងទន្លេ
- ✓ បាត់បង់បន្លែធម្មជាតិនៅតាមដងទន្លេ
- ✓ ជម្លោះនឹងកើតមានឡើង ដោយសារការដណ្តើមដីធ្លាធ្វើស្រែ ចំការ និងដីសំរាប់សង់លំនៅដ្ឋាន
- ✓ ប៉ះពាល់ដល់ការសិក្សារបស់កុមារ
- ✓ ខូចគុណភាពទឹក ការប្រើប្រាស់ទឹកទន្លេអាចប៉ះពាល់ដល់សុខភាពមនុស្ស សត្វ ជាពិសេសស្ត្រី និង កុមារ (កំឡុងពេល សាងសង់ និងប្រតិបត្តិការរបស់ទំនប់ ៥ឆ្នាំដំបូង)
- ✓ ប៉ះពាល់ដល់ផ្លូវចិត្តរបស់សហគមន៍ (ដោយសារសំលេងក្នុងពេលកំពុងសាងសង់ ឬភាពភ័យខ្លាច ទំនប់បាក់)
- ✓ ផ្នែកខាងក្រោមនៃទំនប់ទឹកទន្លេនឹងរីងគោក បាត់បង់ជំរករបស់ត្រី ហើយត្រីមិនអាចបំលាស់ទីបាន និង បាត់បង់ពូជត្រីកំរដូចជាត្រីប៉ាស៊ីអ៊ី ប៉ាវ៉ា.... ជាដើម
- ✓ ការរញ្ជួយដីនឹងអាចកើតមានក្នុងតំបន់អាងស្តុកទឹក និងបាក់ច្រាំងទន្លេ
- ✓ មិនទាន់ដឹងច្បាស់ពីសំណង (ដីស្រែចំការ ដីលំនៅឋាន ដំណាំហូបផ្លែ ផ្ទះ ...)
- ✓ បាត់បង់ទំនៀមទំលាប់-ប្រពៃណីរបស់ដូនតាជនជាតិដើមភាគតិច

- សំរាប់ភូមិស្រែគរ១ និងភូមិស្រែគរ២ ដីដែលផ្តល់សំណងសរុបចំនួន ១.២៣៨ហិកតា សំរាប់៣០០គ្រួសារ ប៉ុន្តែមានដីចំនួនតែ ១០-១៥ហិកតា ប៉ុណ្ណោះដែលអាចបង្កបង្កើនផលបាន។
- ក្រុមហ៊ុនមិនបានប្រជុំឯកភាពជាមួយសហគមន៍ចំពោះទីតាំងលំនៅដ្ឋានថ្មី
- ក្នុងរបាយការណ៍វាយតំលៃផលបប៉ះពាល់ពេញលេញ មិនបានបញ្ជាក់ច្បាស់ថា នៅតាមភូមិនីមួយៗត្រូវផ្តល់ដីស្រែប៉ុន្មានហិកតាដីភូមិ ដីគោរពបូជា ដីចំការ និងដីព្រៃសំរាប់រកផលអនុផលព្រៃឈើជាលក្ខណៈប្រពៃណី...
- ធ្វើអោយបាត់បង់ទំនៀមទំលាប់-ប្រពៃណីរបស់ដូនតាជនជាតិដើមភាគតិច

*២. ដើម្បីបន្ធូបន្ថយហេតុប៉ះពាល់ខាងលើ យើងខ្ញុំទាំងអស់គ្នាមានសំណូមពរដូចខាងក្រោម:*

- ➢ **ចំពោះក្រុមហ៊ុន**

- សុំអោយក្រុមហ៊ុនធ្វើការសិក្សាពីហេតុប៉ះពាល់បរិស្ថានដោយប្រយោលទៅលើសហគមន៍ដែលរស់នៅ ផ្នែកខាងលើ និងខាងក្រោមនៃទំនប់តាមដងទន្លេសេសាន និងទន្លេស្រែពក
- បើសិនជាការសិក្សាឃើញថាមានផលប៉ះពាល់ដល់សហគមន៍ សុំក្រុមហ៊ុនមានវិធានការ រឺ គោលការណ៍ដោះស្រាយមុនធ្វើការសាងសង់ទំនប់
- ត្រូវមានប្រពន្ធ័ទឹកស្អាត ហេដ្ឋារចនាសម្ពន្ធ័ សាលារៀន មណ្ឌលសុខភាព ផ្លូវថ្នល់ ស្ពាន និងបង្គន់អនាម័យ

- ត្រូវផ្តល់អាហារនៅពេលរុះរើទីលំនៅថ្មី
- សូមអោយក្រុមហ៊ុនផ្តល់ប័ណ្ណធានារ៉ាប់រងអាយុជីវិត និងទ្រព្យសម្បត្តិ ដល់សហគមន៍ដែលរស់នៅផ្នែកខាងក្រោមខ្សែទឹកនៃទំនប់
- <u>សូមអោយក្រុមហ៊ុន ផ្តល់សេវាដឹកជញ្ជូន និងជួយរុះរើលំនៅដ្ឋានដល់សហគមន៍ ពីកន្លែងចាស់ទៅ កន្លែងថ្មី</u>
- សូមអោយក្រុមហ៊ុនបើកទ្វារទំនប់នៅរដូវត្រីឡើងចុះ
- សូមអោយក្រុមហ៊ុនផ្តល់សេវាភ្លើងប្រើប្រាស់ដល់សហគមន៍តាមដងទន្លេដោយឥតគិតថ្លៃរយៈពេល១០ឆ្នាំ
- សូមអោយផ្តល់តំលៃសំណងទៅតាមតំលៃទីផ្សារជាក់ស្តែង និងផ្តល់ជូនសហគមន៍មុនសាងសង់ទំនប់
- ***<u>សូមអោយធ្វើការសិក្សាផលប៉ះពាល់ឡើងវិញ និងកែតំរូវ ព្រោះភូមិខ្លះគ្មាននៅក្នុងរបាយការណ៍ ( ទំព័រ៤២ ការរៀបចំដីស្រែមានត្រឹមតែ ៤ភូមិ ក្បាលរមាស ស្រែស្រណុក ច្រប់ និងស្រែគរ )</u>***
- សូមអោយក្រុមហ៊ុន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នពាក់ព័ន្ធផ្សព្វផ្សាយពីគោលការណ៍សំណងពិតប្រាកដដល់សាធារណៈ
- សូមអោយក្រុមហ៊ុនផ្តល់ឥណទាន ដោយគ្មានការប្រាក់សំរាប់ស្តារជីវភាពរស់នៅរបស់សហគមន៍

➢ **ចំពោះរដ្ឋាភិបាល**

- សុំអោយរាជរដ្ឋាភិបាលពិចារណាឡើងវិញសំរាប់ផលប៉ះពាល់ដល់សហគមន៍រស់នៅផ្នែកខាងលើ និងខាងក្រោម លើការសំរេចចិត្តគំរោងសាងសង់ទំនប់វារីអគ្គិសនី**<u>សេសានក្រោម២</u>**
- សុំអោយរាជរដ្ឋាភិបាល ស្វែងរកជម្រើសថ្មីក្រៅពីការសង់ទំនប់វារីអគ្គិសនីនៅលើតួទន្លេ ដោយបង្វែរទៅសង់តាមដងអូរ ឬព្រែកស ដើម្បីបញ្ចៀសផលប៉ះពាល់ធ្ងន់ធ្ងរដល់សហគមន៍
- សហគមន៍យើងខ្ញុំមិនត្រូវការការអភិវឌ្ឍន៍ណាដែលបំផ្លាញដល់ទន្លេទេ ព្រោះទន្លេជាអ្នកមានគុណដល់មនុស្ស និងសត្វ
- សុំអោយរដ្ឋាភិបាលពង្រឹងការអនុវត្តច្បាប់ស្តីពីសិទ្ធិមនុស្ស ជាពិសេសជនជាតិដើមភាគតិច
- សុំអោយរដ្ឋាភិបាលពិចារណា និងទទួលស្គាល់នូវផលប៉ះពាល់ដែលបានកើតឡើងនូវបណ្តាប្រទេសផ្សេងៗ ដើម្បីយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជា
- សហគមន៍ស្នើសុំជ្រើសរើសជំរើសទីតាំងលំនៅដ្ឋានថ្មីដោយខ្លួនឯង
- សុំអោយរដ្ឋាភិបាលបង្កើតប្រពន្ធ័ផ្សព្វផ្សាយព័តិមានតាមសហគមន៍ជាមុន មុននឹងបើកទឹកចេញពីទំនប់

- សុំអោយរដ្ឋាភិបាលបញ្ចូលតំណាងសហគមន៍រងគ្រោះចូលរួមក្នុងសកម្មភាពរបស់គណៈកម្មការសំណង
- សុំអោយរដ្ឋាភិបាល និងម្ចាស់ជំនួយទទួលយកសំណូមពររបស់សហគមន៍យកទៅពិចារណា និងដោះស្រាយ
- សុំអោយរដ្ឋាភិបាល បញ្ឈប់គំរោងអភិវឌ្ឍន៍ទាំងឡាយណាដែលធ្វើអោយប៉ះពាល់ជា អវិជ្ជមានធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

➢ **ស្ថាប័នពាក់ពន្ធ័**

- អាជ្ញាធរមូលដ្ឋាន និងស្ថាបន័ពាក់ពន្ធ័ត្រូវតែធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលវានឹងបង្កឡើងពីគំរោងអភិវឌ្ឍន៍ទាំងនោះដល់សហគមន៍
- ស្ថាប័នពាក់ពន្ធ័មុននឹងអនុមត័គំរោងអភិវឌ្ឍន៍ ត្រូវចុះទៅត្រួតពិនិត្យជាក់ស្តែងដល់ទីតាំងដែលរងផលប៉ះពាល់
- ស្ថាបន័ពាក់ពន្ធ័ត្រូវធ្វើការសហការជាមួយសហគមន៍មុនពេលគំរោងទំនប់វារីអគ្គិសនីដំណើរការ (សំរាប់ធ្វើអ្វី ? សហការរឿងអ្វី)
- ស្ថាបន័ពាក់ពន្ធ័ត្រូវពិនិត្យមើលផលប៉ះពាល់ <u>និងផលសំណងអោយសមស្រប និងការខូចខាត</u>
- ស្ថាប័ន និងមន្ទីរពាក់ពន្ធ័ត្រូវផ្តល់បច្ចេកទេសកសិកម្ម និងសេវាសង្គម ដល់សហគមន៍ដើម្បីស្តារជីវភាពឡើងវិញ
- បង្កើតគណៈកម្មការត្រួតពិនិត្យតាមដានសំណង
- បង្កើតគណៈកម្មការត្រួតពិនិត្យតាមដានជីវភាពជាក់ស្តែង(ហេដ្ឋារចនាសម្ព័ន្ធ មុខរបរ សុខភាព ការអប់រំ ជីវភាពរស់នៅ និងការលំបាកនានា) របស់ប្រជាពលរដ្ឋអោយបានញឹកញាប់ក្រោយពេលទៅរស់ នៅទីតាំងថ្មី

យើងខ្ញុំសង្ឃឹមថា រាល់បញ្ហានិងក្តីបារម្ភ ក៏ដូចជាសំណូមពរ ដែលបានលើកឡើងខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុន និង ភាគីពាក់ព័ន្ធទាំងអស់ នឹងយកទៅពិចារណា ព្រមទាំងធ្វើការដោះស្រាយជូនដល់យើងខ្ញុំដោយក្តីអនុគ្រោះ។

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១

***ព័ត៌មានបន្ថែមសូមទំនាក់ទំនង***

*លោក តន់ ជាង តំណាងសហគមន៍ខេត្តស្ទឹងត្រែង ០១១ ៥៣៤ ២១៣*

*កញ្ញា ណែន សូគីត តំណាងសហគមន៍ ខេត្តរតនៈគីរី ០៩៧ ៧៧ ៩៧ ៣៧៥*